ក្រសួងអប់រំ យុវជន និងកីឡា

គណិតវិទ្យា ថ្នាក់ទី៣

ប៣

# សៀវភៅលំហាត់




ហាមលក់
NOT FOR SALE

ប ៣

មេរៀន

## ទី៨ ដល់ ទី១០

កូនស្វាឆ្លាត

## មេរៀនទី ៨ ពេលវេលា

### រំឭកអំពីការប្រាប់ម៉ោងគត់ និងម៉ោងកន្លះ

1. **ល្បែងតើម៉ោងប៉ុន្មានហើយ?** (លេងជាដៃគូ 👫)

**សម្ភារៈ៖** គ្រាប់ឡុកឡាក់ វត្ថុចំណាំម្នាក់មួយ

**របៀបលេង៖** ទាំងពីរត្រូវដាក់វត្ថុចំណាំនៅត្រង់ចំណុច**ចាប់ផ្ដើម** រួចប្ដូរវេនគ្នាបោះគ្រាប់ឡុកឡាក់ម្ដងម្នាក់ និងផ្លាស់ទីទៅតាមចំនួនដែលបោះបាន ហើយអានម៉ោងនៅលើនាឡិកានោះឱ្យឮៗ។ បើរាប់ទៅចំកន្លែង **បាត់បង់ឱកាស** អ្នកនឹងត្រូវនឹងត្រូវបាត់ឱកាសបោះគ្រាប់ឡុកឡាក់បន្ទាប់។ ដៃគូណាដែលបានទៅដល់ចំណុច**បញ្ចប់**មុនគេ គឺជា**អ្នកឈ្នះ**!



# អាន និងសរសេរម៉ោងក្នុងប្រឡោះក្រិតធំ

**គួរចងចាំ**




ទ្រនិចវែងជាទ្រនិចនាទី ដើរបាន 1ប្រឡោះក្រិតតូច ស្មើនឹង 1នាទី។



ទ្រនិចវែងជាទ្រនិចនាទី ដើរបាន 1ប្រឡោះក្រិតធំ ស្មើនឹង 5នាទី។



**1ម៉ោង = 60នាទី**

មើលវីដេអូ

1. ចូរសរសេរម៉ោងខាងក្រោមតាមរូបនាឡិកា

ឧទាហរណ៍



11:10

11និង10នាទី

ក)



ខ)



គ)



ឃ)



ង)



ច)



ឆ)



ជ)



ឈ)



ញ)



ដ)



# ហ្វឹកហាត់ការអាន និងសរសេរម៉ោងក្នុងប្រឡោះក្រិតធំ

## 1. ល្បែងបង្កើតម៉ោង

**សម្ភារៈ៖ ឃ្នាបក្រដាស**



**របៀបលេង៖**

១) បង្វិលថាសលើកទី១ ដើម្បីបានលេខដែល**ទ្រនិចម៉ោង**ចង្អុលទៅ។

២) បង្វិលថាសលើកទី២ ដើម្បីបានលេខដែល**ទ្រនិចនាទី**ចង្អុលទៅ។

៣) សរសេរម៉ោងដាក់ក្នុងប្រអប់នៅខាងក្រោមនាឡិកា និងគូសទ្រនិចនាឡិកាឱ្យត្រូវតាមម៉ោងនោះ។

៤) ឱ្យគ្រូ ឬឪពុកម្ដាយជួយផ្ទៀងផ្ទាត់ចម្លើយ។ បើត្រឹមត្រូវ ផាត់ព៌ណរូបផ្កាយដែលនៅជាប់នឹងប្រអប់នោះ។

**ឧទាហរណ៍**




មើលវីដេអូ








# អាន និងសរសេរពេលវេលាជាម៉ោងនិងនាទី

**គួរចងចាំ**




ទ្រនិចវែងជាទ្រនិចនាទី ដើរបាន 1 ប្រឡោះក្រិតតូចស្មើនិង 1នាទី។

**60នាទី = 1ម៉ោង**

**អានថា**

**ម៉ោង 9 និង 27នាទី**

**យើងសរសេរ**

**9:27**

មើលវីដេអូ

1. ចូរអានម៉ោងនិងបំពេញប្រអប់

ក)



**អានថា** ______

**សរសេរ** ______

ខ)



**អានថា** ______

**សរសេរ** ______

គ)



**អានថា** ______

**សរសេរ** ______

ឃ)



**អានថា** ______

**សរសេរ** ______

ង)



**អានថា** ______

**សរសេរ** ______

---

2. ចូរផ្គូផ្គងនាឡិកាខាងក្រោម បន្ទាប់មក សរសេរម៉ោងនៅក្នុងប្រអប់

មើលវីដេអូ

**4:33** | **8:51** | **10:12** (ឧទាហរណ៍) | **7:27** | **3:43**

ក)



ខ)



គ)



ឃ)



ង)



**ឧទាហរណ៍**

ក) អានថា ម៉ោង 10 និង 12នាទី

សរសេរ **10:12**

ខ) អានថា ______ សរសេរ ______

គ) អានថា ______ សរសេរ ______

ឃ) អានថា ______ សរសេរ ______

ង) អានថា ______ សរសេរ ______

# ប្តូរម៉ោងពីប្រព័ន្ធ 24ម៉ោងទៅជាប្រព័ន្ធ 12ម៉ោង

**គួរចងចាំ**

**09:00** — **គឺ ម៉ោង 9ព្រឹក**



**21:00** — **គឺ ម៉ោង 9យប់**



ដើម្បីប្តូរម៉ោងពីប្រព័ន្ធ 24ម៉ោង (**ចាប់ពីម៉ោង 13:00 រហូតដល់កណ្តាលអធ្រាត្រ**)
ទៅជាប្រព័ន្ធ 12ម៉ោង យើងត្រូវដកចេញ 12ម៉ោង។

ដើម្បីប្តូរពី **ម៉ោង 21:00** ទៅជាប្រព័ន្ធ **12ម៉ោង** យើងត្រូវ**យកម៉ោងនោះដកចេញ 12 ម៉ោង**។
ដូចនេះ **ម៉ោង 21:00 គឺ ម៉ោង 9យប់**។

មើលវីដេអូ

1. ចូរបំពេញប្រអប់

**ឧទាហរណ៍**

17:00 គឺម៉ោង 5 ល្ងាច

18:51 គឺម៉ោង 6 និង 51នាទី យប់

ក) 23:00 គឺម៉ោង ________ យប់

ខ) 14:16 គឺម៉ោង ________ រសៀល

គ) 21:00 គឺម៉ោង ________ យប់

ឃ) 20:40 គឺម៉ោង ________ យប់

ង) 13:32 គឺម៉ោង ________ រសៀល

មើលវីដេអូ

2. ចូរគូរទ្រនិចនាឡិកាឱ្យត្រូវតាមម៉ោង និងវង់លើពាក្យ ព្រឹក រសៀល ឬយប់

**ឧទាហរណ៍**



14:45

ព្រឹក (រសៀល) យប់

ក)



17:15

ព្រឹក រសៀល យប់

ខ)



11:05

ព្រឹក រសៀល យប់

គ)



22:35

ព្រឹក រសៀល យប់

ឃ)



16:55

ព្រឹក រសៀល យប់

ង)



07:40

ព្រឹក រសៀល យប់

# អានតារាងពេលវេលា

1. ចូរមើលតារាងខាងក្រោម និងឆ្លើយសំណួរ



មើលវីដេអូ

| រថយន្ត | ទិសដៅ | ម៉ោងចេញដំណើរ | ម៉ោងទៅដល់ |
|---|---|---|---|
| 1 | ភ្នំពេញ - បានលុង | **06:00** | **15:15** |
| 2 | ភ្នំពេញ - ក្រចេះ | **06:30** | **14:00** |
| 3 | ភ្នំពេញ - សែនមនោរម្យ | **07:00** | **14:20** |
| 4 | ភ្នំពេញ - ពោធិ៍សាត់ | **07:30** | **10:45** |
| 5 | ភ្នំពេញ - កំពង់ចាម | **13:30** | **16:00** |
| 6 | ភ្នំពេញ - កំពត | **15:00** | **19:10** |

ក) តើរថយន្តដំបូងគេចេញដំណើរឆ្ពោះទៅណា? រថយន្តនេះឆ្ពោះទៅ________________________ ។

ខ) តើរថយន្តទៅខេត្តពោធិ៍សាត់ចេញដំណើរនៅម៉ោងប៉ុន្មាន? ចេញដំណើរនៅម៉ោង_____________ ។

គ) តើរថយន្តទៅខេត្តកំពតនឹងទៅដល់នៅម៉ោងប៉ុន្មាន? រថយន្តនឹងទៅដល់នៅម៉ោង _____________ ។

ឃ) តើរថយន្តដែលចេញដំណើរនៅម៉ោង 7:00 ឆ្ពោះទៅទីណា? ឆ្ពោះទៅ________________________។

ង) តើមានរថយន្តប៉ុន្មានដែលចេញដំណើរនៅពេលរសៀល? រថយន្តពេលរសៀលមានចំនួន_________។

2. ចូរគណនារយៈពេលធ្វើដំណើរនីមួយៗខាងក្រោម

មើលវីដេអូ

**គួរចងចាំ**




**ការធ្វើដំណើរពីភ្នំពេញទៅពោធិ៍សាត់**

១) ចេញដំណើរនៅម៉ោង 07:30 យើងរាប់បន្ថែមម្តង១ម៉ោងគឺ 08:30 (1); 09:30 (2); 10:30 (3) យើងបាន **3ម៉ោង**។

២) រាប់បន្ថែមចំនួននាទី។ 10:30 ដល់ 10:45 គឺ **15នាទី**។

ដូចនេះរយៈពេលធ្វើដំណើរសរុបគឺ **3ម៉ោង 15នាទី**។

ក) ពីភ្នំពេញទៅបានលុងប្រើរយៈពេល_________។ ខ) ពីភ្នំពេញទៅក្រចេះមានប្រើរយៈពេល_________។

គ) ពីភ្នំពេញទៅសែនមនោរម្យប្រើរយៈពេល_______។ ឃ) ពីភ្នំពេញទៅពោធិ៍សាត់ប្រើរយៈពេល______។

ង) ពីភ្នំពេញទៅកំពង់ចាមប្រើរយៈពេល____________។ ច) ពីភ្នំពេញទៅកំពតប្រើរយៈពេល_________។

ឆ) តើការធ្វើដំណើរក្នុងទិសដៅមួយណាដែលឆ្ងាយជាងគេ? ការធ្វើដំណើរដែលឆ្ងាយជាងគេគឺ________________។

ជ) តើការធ្វើដំណើរក្នុងទិសដៅមួយណាដែលជិតជាងគេ? ការធ្វើដំណើរដែលជិតជាងគេគឺ__________________។

## មេរៀនទី ១ វិធីគុណ

### ហ្វឹកហាត់ការគុណចំនួននៅថ្នាក់ទី២

1. **ល្បែងជួយតម្រៀបលេខមនុស្សយន្ត**

**របៀបលេង៖ សូមចងចាំថា**ចំនួនដែលនៅលើខ្លួនរបស់មនុស្សយន្តគឺជាផលគុណរបស់មេគុណ **3; 4** និង **5**។

១) បំពេញចំនួនក្នុងប្រអប់ និងគណនាផលគុណដើម្បីរកចំនួនដែលនៅសល់តែមួយគត់លើខ្លួនមនុស្សយន្ត។

២) ឆូតលេខនៅលើខ្លួនមនុស្សយន្តដែលត្រូវគ្នាជាមួយផលគុណនោះ។

៣) ចំនួនដែលនៅសល់គឺ ☐

មើលវីដេអូ




2. ចូរបំពេញផលគុណក្នុងប្រអប់

**គួរចងចាំ**

| ខ្ទង់ដប់ | ខ្ទង់រាយ |
|---|---|
| 2 | 3 |
| | 3 |
| | |

ជំហានទី១

| ខ្ទង់ដប់ | ខ្ទង់រាយ |
|---|---|
| 2 | 3 |
| x | 3 |
| | 9 |

ជំហានទី២

3 x 3 = 9

| ខ្ទង់ដប់ | ខ្ទង់រាយ |
|---|---|
| 2 | 3 |
| x | 3 |
| 6 | 9 |

ជំហានទី៣

2 x 3 = 6

ក) 22 x 3 = ☐

ខ) 31 x 2 = ☐

គ) 12 x 4 = ☐

ឃ) 30 x 3 = ☐

ង) 11 x 5 = ☐

ច) 43 x 2 = ☐

មើលវីដេអូ

3. ចូរផ្គូផ្គងល្បះលេខគុណនៅលើខ្លួនមេអំបៅទៅនឹងផលគុណនៅលើផ្កា រួចគូរវង់មេអំបៅដែលនៅសល់



# ការគុណនឹង 6

**គួរចងចាំ**






រាប់បន្ថែមម្ដង 6 ចំនួន 5ដង។
6 + 6 + 6 + 6 + 6 = 30
ផ្លែចេកមាន 6 ប្រាំដង។

យើងនិយាយថា៖
**ប្រាំមួយប្រាំដងស្មើនឹងសាមសិប។**
យើងសរសេរ៖ **6 x 5 = 30**

**“X” ការគុណគឺជាការបូកចំនួនដដែលៗច្រើនដង។**

| | | | | |
|---|---|---|---|---|
| 6 | x | 1 | = | 6 |
| 6 | x | 2 | = | 12 |
| 6 | x | 3 | = | 18 |
| 6 | x | 4 | = | 24 |
| 6 | x | 5 | = | 30 |
| 6 | x | 6 | = | 36 |
| 6 | x | 7 | = | 42 |
| 6 | x | 8 | = | 48 |
| 6 | x | 9 | = | 54 |
| 6 | x | 10 | = | 60 |

មើលវីដេអូ

1. ចូរមើលរូបភាព និងបំពេញចំនួនក្នុងប្រអប់

ក) 

☐ + 6 + ☐ + ☐ = ☐

6 x ☐ = ☐

ខ) 

☐ + ☐ + 6 + ☐ + ☐ + ☐ + ☐ = ☐

6 x ☐ = ☐

2. ចូរបំពេញចំនួនក្នុងប្រអប់ (អាចប្រើបន្ទាត់ចំនួនជាជំនួយក៏បាន)

មើលវីដេអូ

ក)

ឧទាហរណ៍

6 x 2 = 12




ខ)

ឧទាហរណ៍

6 x 1 = 6



# ហ្វឹកហាត់ការគុណនឹង 6

## 1. ល្បែងបង្កើតលំនាំគំរូដោយប្រើមេគុណ 6

**របៀបលេង៖**

១) សូត្រមេគុណ 6 និងផាត់ពណ៌ក្រឡានៅក្នុងតារាងការេ 100 ដែលមានតម្លៃលេខត្រូវគ្នាជាមួយផលគុណនោះ។

២) បំពេញប្រអប់ដោយយកតែលេខនៅខ្ទង់រាយនៃចំនួនដែលផាត់ពណ៌។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |

៣) មើលទៅលំនាំគំរូនិងផាត់ពណ៌បន្តដោយចាប់ផ្តើមចេញពីក្រឡាលេខ 60 និងរាប់បន្ថែមម្តង 6។

មើលវីដេអូ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
| 31 | 32 | 33 | 34 | 35 | 36 | 37 | 38 | 39 | 40 |
| 41 | 42 | 43 | 44 | 45 | 46 | 47 | 48 | 49 | 50 |
| 51 | 52 | 53 | 54 | 55 | 56 | 57 | 58 | 59 | 60 |
| 61 | 62 | 63 | 64 | 65 | 66 | 67 | 68 | 69 | 70 |
| 71 | 72 | 73 | 74 | 75 | 76 | 77 | 78 | 79 | 80 |
| 81 | 82 | 83 | 84 | 85 | 86 | 87 | 88 | 89 | 90 |
| 91 | 92 | 93 | 94 | 95 | 96 | 97 | 98 | 99 | 100 |

**ឧទាហរណ៍**

**ការប្រើមេគុណ 3**

១)

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
| 31 | 32 | 33 | 34 | 35 | 36 | 37 | 38 | 39 | 40 |
| 41 | 42 | 43 | 44 | 45 | 46 | 47 | 48 | 49 | 50 |
| 51 | 52 | 53 | 54 | 55 | 56 | 57 | 58 | 59 | 60 |
| 61 | 62 | 63 | 64 | 65 | 66 | 67 | 68 | 69 | 70 |
| 71 | 72 | 73 | 74 | 75 | 76 | 77 | 78 | 79 | 80 |
| 81 | 82 | 83 | 84 | 85 | 86 | 87 | 88 | 89 | 90 |
| 91 | 92 | 93 | 94 | 95 | 96 | 97 | 98 | 99 | 100 |

២)

| | | | | |
|---|---|---|---|---|
| 3 | 6 | 9 | 2 | 5 |
| 8 | 1 | 4 | 7 | 0 |

៣)

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
| 31 | 32 | 33 | 34 | 35 | 36 | 37 | 38 | 39 | 40 |
| 41 | 42 | 43 | 44 | 45 | 46 | 47 | 48 | 49 | 50 |
| 51 | 52 | 53 | 54 | 55 | 56 | 57 | 58 | 59 | 60 |
| 61 | 62 | 63 | 64 | 65 | 66 | 67 | 68 | 69 | 70 |
| 71 | 72 | 73 | 74 | 75 | 76 | 77 | 78 | 79 | 80 |
| 81 | 82 | 83 | 84 | 85 | 86 | 87 | 88 | 89 | 90 |
| 91 | 92 | 93 | 94 | 95 | 96 | 97 | 98 | 99 | 100 |

## 2. ល្បែងស្វែងរកចំនួនអាថ៌កំបាំង

មើលវីដេអូ

**របៀបលេង៖** ១) ស្វែងរក និងផាត់ពណ៌ចំនួនដែលជាផលគុណរបស់មេគុណ 6។

២) ចំនួនអាថ៌កំបាំងដែលអ្នករកឃើញគឺ ☐។

៣) បំពេញល្បះលេខដោយយកចំនួនអាថ៌កំបាំងនោះដាក់ជាផលគុណ។ 6 x ☐ = ☐




**ឧទាហរណ៍**

១)



២) ចំនួនអាថ៌កំបាំងគឺ៖ 18

៣) 6 x 3 = 18

# ការគុណនឹង 7

**គួរចងចាំ**




រាប់បន្ថែមម្តង 7 ចំនួន 5ដង។

7 + 7 + 7 + 7 + 7 = 35

ស្ករគ្រាប់មាន 7 ប្រាំដង។

យើងនិយាយថា**ប្រាំពីរប្រាំដងស្មើនឹងសាមសិបប្រាំ**។ យើងសរសេរ៖ **7 x 5 = 35**។

**“X” ការគុណគឺជាការបូកចំនួនដដែលៗច្រើនដង។**

| | | | | |
|---|---|---|---|---|
| 7 | x | 1 | = | 7 |
| 7 | x | 2 | = | 14 |
| 7 | x | 3 | = | 21 |
| 7 | x | 4 | = | 28 |
| 7 | x | 5 | = | 35 |
| 7 | x | 6 | = | 42 |
| 7 | x | 7 | = | 49 |
| 7 | x | 8 | = | 56 |
| 7 | x | 9 | = | 63 |
| 7 | x | 10 | = | 70 |

មើលវីដេអូ

1. ចូរមើលរូបភាព និងបំពេញចំនួនក្នុងប្រអប់

ក)



☐ + 7 + ☐ + ☐ + ☐ + ☐ = ☐

7 x ☐ = ☐

ខ)



☐ + ☐ + ☐ + ☐ = ☐

7 x ☐ = ☐

2. ចូរបំពេញចំនួនក្នុងប្រអប់ (អាចប្រើបន្ទាត់ចំនួនជាជំនួយក៏បាន)

មើលវីដេអូ

ក)




ខ)




3. ចូរបំពេញចំនួនក្នុងប្រអប់

ក) 7 x ☐ = 42 ខ) 7 x 8 = ☐ គ) 7 x ☐ = 21 ឃ) 7 x 9 = ☐

# ហ្វឹកហាត់ការគុណនឹង 7

1. **ល្បែងបង្កើតលំនាំគំរូដោយប្រើមេគុណ 7**

**របៀបលេង៖**

១) សូត្រមេគុណ 7 និងផាត់ពណ៌ក្រឡានៅក្នុងតារាងការេ 100 ដែលមានតម្លៃលេខត្រូវគ្នាជាមួយផលគុណនោះ។

២) បំពេញប្រអប់ដោយយកតែលេខនៅខ្ទង់រាយនៃចំនួនដែលផាត់ពណ៌។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |

៣) មើលទៅលំនាំគំរូនិងផាត់ពណ៌បន្តដោយចាប់ផ្តើមចេញពីក្រឡាលេខ 70 និងរាប់បន្ថែមម្តង 7។

មើលវីដេអូ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
| 31 | 32 | 33 | 34 | 35 | 36 | 37 | 38 | 39 | 40 |
| 41 | 42 | 43 | 44 | 45 | 46 | 47 | 48 | 49 | 50 |
| 51 | 52 | 53 | 54 | 55 | 56 | 57 | 58 | 59 | 60 |
| 61 | 62 | 63 | 64 | 65 | 66 | 67 | 68 | 69 | 70 |
| 71 | 72 | 73 | 74 | 75 | 76 | 77 | 78 | 79 | 80 |
| 81 | 82 | 83 | 84 | 85 | 86 | 87 | 88 | 89 | 90 |
| 91 | 92 | 93 | 94 | 95 | 96 | 97 | 98 | 99 | 100 |

2. ចូរបំពេញចំនួនក្នុងប្រអប់

ក) 7 x ☐ = 28

ខ) 7 x ☐ = 42

គ) 6 x 9 = ☐

ឃ) 6 x 8 = ☐

ង) 7 x ☐ = 63

ច) 6 x ☐ = 18

ឆ) 6 x 7 = ☐

ជ) 7 x ☐ = 49

ឈ) 7 x 8 = ☐

ញ) 7 x ☐ = 21

3. **ល្បែងស្វែងរកចំនួនអាថ៌កំបាំង**

មើលវីដេអូ

**របៀបលេង៖** ១) ស្វែងរក និងផាត់ពណ៌ចំនួនដែលជាផលគុណរបស់មេគុណ 7។

២) ចំនួនអាថ៌កំបាំងដែលអ្នករកឃើញគឺ ☐ ។

៣) បំពេញល្បះលេខដោយយកចំនួនអាថ៌កំបាំងនោះដាក់ជាផលគុណ។ 7 x ☐ = ☐



# ការគុណនឹង 8

**គួរចងចាំ**




រាប់បន្ថែមម្តង 8 ចំនួន 5ដង។

8 + 8 + 8 + 8 + 8 = 40

ជើងពីងពាងមាន 8 ប្រាំដង។

យើងនិយាយថា**ប្រាំបីប្រាំដងស្មើនឹងសែសិប**។ យើងសរសេរៈ **8 x 5 = 40**។

**"X" ការគុណគឺជាការបូកចំនួនដដែលៗច្រើនដង។**

| | | | | |
|---|---|---|---|---|
| 8 | x 1 | = | 8 |
| 8 | x 2 | = | 16 |
| 8 | x 3 | = | 24 |
| 8 | x 4 | = | 32 |
| 8 | x 5 | = | 40 |
| 8 | x 6 | = | 48 |
| 8 | x 7 | = | 56 |
| 8 | x 8 | = | 64 |
| 8 | x 9 | = | 72 |
| 8 | x 10 | = | 80 |

មើលវីដេអូ

1. ចូរមើលរូបភាព និងបំពេញចំនួនក្នុងប្រអប់

ក)



8 + ☐ + ☐ + ☐ = ☐

8 x ☐ = ☐

ខ)



☐ + ☐ + ☐ + ☐ + ☐ + ☐ + ☐ = ☐

8 x ☐ = ☐

2. ចូរបំពេញចំនួនក្នុងប្រអប់ (អាចប្រើបន្ទាត់ចំនួនជាជំនួយក៏បាន)

មើលវីដេអូ

ក)




ខ)



# ហ្វឹកហាត់ការគុណនឹង 8

## 1. ល្បែងបង្កើតលំនាំគំរូដោយប្រើមេគុណ 8

**របៀបលេង៖**

១) សូត្រមេគុណ 8 និងផាត់ពណ៌ក្រឡានៅក្នុងតារាងការេ 100 ដែលមានតម្លៃលេខត្រូវគ្នាជាមួយផលគុណនោះ។

២) បំពេញប្រអប់ដោយយកតែលេខនៅខ្ទង់រាយនៃចំនួនដែលផាត់ពណ៌។

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | |

៣) មើលទៅលំនាំគំរូនិងផាត់ពណ៌បន្តដោយចាប់ផ្តើមចេញពីក្រឡាលេខ 80 និងរាប់បន្ថែមម្តង 8។

មើលវីដេអូ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
| 31 | 32 | 33 | 34 | 35 | 36 | 37 | 38 | 39 | 40 |
| 41 | 42 | 43 | 44 | 45 | 46 | 47 | 48 | 49 | 50 |
| 51 | 52 | 53 | 54 | 55 | 56 | 57 | 58 | 59 | 60 |
| 61 | 62 | 63 | 64 | 65 | 66 | 67 | 68 | 69 | 70 |
| 71 | 72 | 73 | 74 | 75 | 76 | 77 | 78 | 79 | 80 |
| 81 | 82 | 83 | 84 | 85 | 86 | 87 | 88 | 89 | 90 |
| 91 | 92 | 93 | 94 | 95 | 96 | 97 | 98 | 99 | 100 |

## 2. ចូរបំពេញចំនួនក្នុងប្រអប់

ក) 8 x ☐ = 40

ខ) 8 x ☐ = 64

គ) 6 x 6 = ☐

ឃ) 7 x 6 = ☐

ង) 8 x ☐ = 32

ច) 7 x ☐ = 63

ឆ) 6 x 4 = ☐

ជ) 8 x ☐ = 72

ឈ) 8 x 6 = ☐

ញ) 8 x ☐ = 56

## 3. ល្បែងស្វែងរកចំនួនអាថ៌កំបាំង

មើលវីដេអូ

**របៀបលេង៖** ១) ស្វែងរក និងផាត់ពណ៌ចំនួនដែលជាផលគុណរបស់មេគុណ 8។

២) ចំនួនអាថ៌កំបាំងដែលអ្នករកឃើញគឺ ☐ ។

៣) បំពេញល្បះលេខដោយយកចំនួនអាថ៌កំបាំងនោះដាក់ជាផលគុណ។ 8 x ☐ = ☐

74 38 16 47 24 42 13 40 56 27 35 5 8 24 33 32 6 16 55 62 48 64 46 80 15 8 56 32 40 64 48 72 51 55 72 22 12

# ការគុណនឹង 9

**គួរចងចាំ**






រាប់បន្ថែមម្តង 9 ចំនួន 4ដង។

9 + 9 + 9 + 9 = 36

ផ្កាឈូករ័ត្នមាន 9 បួនដង។

យើងនិយាយថា**ប្រាំបួនបួនដងស្មើនឹងសាមសិបប្រាំមួយ**។ សរសេរ៖ **9 x 4 = 36**។

**"X" ការគុណគឺជាការបូកចំនួនដដែលៗច្រើនដង។**

| | | | | |
|---|---|---|---|---|
| 9 | x | 1 | = | 9 |
| 9 | x | 2 | = | 18 |
| 9 | x | 3 | = | 27 |
| 9 | x | 4 | = | 36 |
| 9 | x | 5 | = | 45 |
| 9 | x | 6 | = | 54 |
| 9 | x | 7 | = | 63 |
| 9 | x | 8 | = | 72 |
| 9 | x | 9 | = | 81 |
| 9 | x | 10 | = | 90 |

មើលវីដេអូ

1. ចូរមើលរូបភាព និងបំពេញចំនួនក្នុងប្រអប់

ក) 

9 + ☐ + ☐ + ☐ + ☐ = ☐

9 x ☐ = ☐

ខ) 

☐ + ☐ + ☐ + ☐ + ☐ + ☐ + ☐ = ☐

9 x ☐ = ☐

មើលវីដេអូ

2. ចូរបំពេញចំនួនក្នុងប្រអប់ (អាចប្រើបន្ទាត់ចំនួនជាជំនួយក៏បាន)

ក) 


ខ) 

# ហ្វឹកហាត់ការគុណនឹង 9

## 1. ល្បែងបង្កើតលំនាំគំរូដោយប្រើមេគុណ 9

**របៀបលេង៖**

១) សូត្រមេគុណ 9 និងផាត់ពណ៌ក្រឡានៅក្នុងតារាងការេ 100 ដែលមានតម្លៃលេខត្រូវគ្នាជាមួយផលគុណនោះ។

២) បំពេញប្រអប់ដោយយកតែលេខនៅខ្ទង់រាយនៃចំនួនដែលផាត់ពណ៌។

☐ ☐ ☐ ☐ ☐ ☐ ☐ ☐ ☐ ☐

៣) មើលទៅលំនាំគំរូនិងផាត់ពណ៌បន្តដោយចាប់ផ្ដើមចេញពីក្រឡាលេខ 90 និងរាប់បន្ថែមម្ដង 9។

មើលវីដេអូ

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| 11 | 12 | 13 | 14 | 15 | 16 | 17 | 18 | 19 | 20 |
| 21 | 22 | 23 | 24 | 25 | 26 | 27 | 28 | 29 | 30 |
| 31 | 32 | 33 | 34 | 35 | 36 | 37 | 38 | 39 | 40 |
| 41 | 42 | 43 | 44 | 45 | 46 | 47 | 48 | 49 | 50 |
| 51 | 52 | 53 | 54 | 55 | 56 | 57 | 58 | 59 | 60 |
| 61 | 62 | 63 | 64 | 65 | 66 | 67 | 68 | 69 | 70 |
| 71 | 72 | 73 | 74 | 75 | 76 | 77 | 78 | 79 | 80 |
| 81 | 82 | 83 | 84 | 85 | 86 | 87 | 88 | 89 | 90 |
| 91 | 92 | 93 | 94 | 95 | 96 | 97 | 98 | 99 | 100 |

## 2. ចូរបំពេញចំនួនក្នុងប្រអប់

ក) 9 x ☐ = 72

ខ) 9 x ☐ = 27

គ) 6 x 9 = ☐

ឃ) 7 x 8 = ☐

ង) 9 x ☐ = 81

ច) 9 x ☐ = 36

ឆ) 6 x 5 = ☐

ជ) 7 x ☐ = 63

ឈ) 8 x 6 = ☐

ញ) 9 x ☐ = 54

## 3. ល្បែងស្វែងរកចំនួនអាថ៌កំបាំង

មើលវីដេអូ

**របៀបលេង៖** ១) ស្វែងរក និងផាត់ពណ៌ចំនួនដែលជាផលគុណរបស់មេគុណ 9។

២) ចំនួនអាថ៌កំបាំងដែលអ្នករកឃើញគឺ ☐ ។

៣) បំពេញល្បះលេខដោយយកចំនួនអាថ៌កំបាំងនោះដាក់ជាផលគុណ។ 9 x ☐ = ☐



# វិធីគុណមានលក្ខណៈត្រឡប់

1. **ល្បែងប្តូរលំដាប់តួគុណ** (លេងជាដៃគូ)

**សម្ភារៈ៖** តារាងគុណនៅខាងក្រោមទំព័រនេះ ក្តារឆ្នួ ឬក្រដាស

**របៀបលេង៖**

១) **សិស្ស ក** ជ្រើសរើសលេខនៅក្នុងជួរដេកទី១ និងជួរឈរទី១ រួចគណនារកផលគុណដោយសរសេរដាក់នៅលើក្តារឆ្នួន។

២) **សិស្ស ខ** ត្រឡប់តួគុណ និងគណនាផលគុណដាក់នៅលើក្តារឆ្នួនផ្សេងមួយទៀត។

៣) ផ្ទៀងផ្ទាត់ចម្លើយនៅក្នុងតារាងគុណនៅខាងក្រោម ដោយដាក់ម្រាមដៃស្តាំនៅលើលេខក្នុងជួដេកទី១ និងម្រាមដៃឆ្វេងនៅលើលេខក្នុងជួរឈរទី១។

៤) រំកិលម្រាមដៃឆ្វេងទៅខាងស្តាំ និងអូសម្រាមដៃស្តាំចុះក្រោមរហូតដល់ម្រាមដៃជួបគ្នា វាជាក្រឡាចម្លើយ។




| x | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
|---|---|---|---|---|---|---|---|---|---|---|
| 1 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| 2 | 2 | 4 | 6 | 8 | 10 | 12 | 14 | 16 | 18 | 20 |
| 3 | 3 | 6 | 9 | 12 | 15 | 18 | 21 | 24 | 27 | 30 |
| 4 | 4 | 8 | 12 | 16 | 20 | 24 | 28 | 32 | 36 | 40 |
| 5 | 5 | 10 | 15 | 20 | 25 | 30 | 35 | 40 | 45 | 50 |
| 6 | 6 | 12 | 18 | 24 | 30 | 36 | 42 | 48 | 54 | 60 |
| 7 | 7 | 14 | 21 | 28 | 35 | 42 | 49 | 56 | 63 | 70 |
| 8 | 8 | 16 | 24 | 32 | 40 | 48 | 56 | 64 | 72 | 80 |
| 9 | 9 | 18 | 27 | 36 | 45 | 54 | 63 | 72 | 81 | 90 |
| 10 | 10 | 20 | 30 | 40 | 50 | 60 | 70 | 80 | 90 | 100 |

មើលវីដេអូ

# ការគុណចំនួនមានលេខ 2ខ្ទង់នឹង 1ខ្ទង់មានត្រាទុក

**គួរចងចាំ**



ពងទាមួយកញ្ច្រែងមាន 24គ្រាប់។ តើពងទា 6កញ្ច្រែងមានប៉ុន្មានគ្រាប់ ?

24 x 6 = ☐

**ដំបូងយើងគុណខ្ទង់រាយ បន្ទាប់មកគុណខ្ទង់ដប់។**

$$\begin{array}{r} {}^{2}\\ 24 \\ \times\ 6 \\ \hline 144 \end{array}$$

6 គុណនឹង 4 ស្មើនឹង 24 សរសេរលេខ 4 ត្រាទុក 2។

6 គុណនឹង 2 ស្មើនឹង 12 រួចបូកនឹង 2 ស្មើនឹង 14 សរសេរលេខ 14។

ដូចនេះពងទាសរុបមានចំនួន **144គ្រាប់**។

មើលវីដេអូ

1. ចូរបំពេញផលគុណក្នុងប្រអប់

ក) 15 x 2 = ☐ ខ) 54 x 5 = ☐ គ) 27 x 3 = ☐

ឃ) 34 x 4 = ☐ ង) 85 x 3 = ☐ ច) 68 x 2 = ☐

2. ចូរបំពេញផលគុណក្នុងប្រអប់

ក) 82 x 4 = ☐ ខ) 28 x 5 = ☐ គ) 94 x 2 = ☐

ឃ) 37 x 5 = ☐ ង) 46 x 3 = ☐ ច) 79 x 4 = ☐

3. ចូរបំពេញផលគុណក្នុងប្រអប់

ក) 32 x 6 = ☐ ខ) 53 x 6 = ☐ គ) 70 x 6 = ☐

ឃ) 46 x 6 = ☐ ង) 18 x 6 = ☐ ច) 49 x 6 = ☐

4. ចូរបំពេញផលគុណក្នុងប្រអប់

ក) 53 x 7 = ☐ ខ) 24 x 7 = ☐ គ) 17 x 7 = ☐

ឃ) 42 x 7 = ☐ ង) 80 x 7 = ☐ ច) 69 x 7 = ☐

5. ចូរបំពេញផលគុណក្នុងប្រអប់

ក) 54 x 8 = ☐ ខ) 62 x 8 = ☐ គ) 38 x 8 = ☐

ឃ) 40 x 8 = ☐ ង) 19 x 8 = ☐ ច) 75 x 8 = ☐

6. ចូរបំពេញផលគុណក្នុងប្រអប់

ក) 25 x 9 = ☐ ខ) 30 x 9 = ☐ គ) 17 x 9 = ☐

ឃ) 46 x 9 = ☐ ង) 59 x 9 = ☐ ច) 81 x 9 = ☐

7. ចូរដោះស្រាយចំណោទខាងក្រោម

ក) ពងមាន់មួយប្រអប់មាន 36គ្រាប់។
តើពងមាន់ 6ប្រអប់មានប៉ុន្មានគ្រាប់ ?
ពងមាន់សរុបមានចំនួន ☐ គ្រាប់។

ខ) ស៊ីមដើរក្នុងមួយថ្ងៃបាន 13គម។
តើក្នុង4ថ្ងៃគាត់ដើរបានប៉ុន្មានគីឡូម៉ែត្រ ?
ស៊ីមដើរបានចម្ងាយសរុប ☐ គម។

មើលវីដេអូ

# ហ្វឹកហាត់ការគុណចំនួនមានលេខ 2ខ្ទង់នឹង 1ខ្ទង់មានត្រាទុក

## 1. ល្បែងស្វែងរករូបភាពអាថ៌កំបាំង

មើលវីដេអូ

**របៀបលេង៖**

១) គណនាផលគុណពី ក) ដល់ ដ)។

២) ផ្ទៀងផ្ទាត់ផលគុណជាមួយចំនួននៅក្នុងតារាង និងផាត់ពណ៌ក្រឡានោះ។

ក) 73 x 6 = ☐

ខ) 54 x 8 = ☐

គ) 35 x 4 = ☐

ឃ) 49 x 7 = ☐

ង) 93 x 5 = ☐

ច) 86 x 9 = ☐

ឆ) 48 x 3 = ☐

ជ) 37 x 7 = ☐

ឈ) 85 x 6 = ☐

ញ) 76 x 2 = ☐

ដ) 28 x 8 = ☐




៣) នៅពេលផាត់ពណ៌គ្រប់ចំនួន រូបភាពដែលអ្នករកឃើញគឺ៖_______________។

## 2. ល្បែងគុណចំនួនរីករាយ

មើលវីដេអូ

**របៀបលេង៖**

១) បង្វិលថាសនិងបំពេញចំនួនក្នុងប្រអប់។

២) គណនារកផលគុណ។

៣) ផ្ទៀងផ្ទាត់ផលគុណជាមួយឪពុកម្តាយ ឬបង។




☐ x 7 = ☐

☐ x 6 = ☐

☐ x 5 = ☐

☐ x 4 = ☐

☐ x 3 = ☐

☐ x 3 = ☐

☐ x 9 = ☐

☐ x 6 = ☐

☐ x 2 = ☐

☐ x 8 = ☐

# ការគុណចំនួនមានលេខ 3ខ្ទង់នឹង 1ខ្ទង់គ្មាន និងមានត្រាទុក

**គួរចងចាំ**

ពូស៊ីមលក់គ្រាប់កាហ្វេក្នុងមួយថ្ងៃបាន 120គក។ តើក្នុង 4ថ្ងៃ គាត់លក់គ្រាប់កាហ្វេសរុបបានចំនួនប៉ុន្មានគីឡូក្រាម?

120 x 4 = ☐



| | |
|---|---|
| 120 | 4 x 0 = 0 សរសេរលេខ 0។ |
| x 4 | 4 x 2 = 8 សរសេរលេខ 8។ |
| 480 | 4 x 1 = 4 សរសេរលេខ 4។ |
| | 120 x 4 = 480 |

ដូចនេះពូស៊ីមលក់គ្រាប់កាហ្វេសរុបបានចំនួន 480គក។

មើលវីដេអូ

1. ចូរបំពេញផលគុណក្នុងប្រអប់

ក) 432 x 2 = ☐ ខ) 122 x 4 = ☐ គ) 213 x 3 = ☐

ឃ) 101 x 5 = ☐ ង) 330 x 3 = ☐ ច) 301 x 2 = ☐

ឆ) 201 x 4 = ☐ ជ) 312 x 3 = ☐ ឈ) 110 x 5 = ☐

**គួរចងចាំ**

កសិករម្នាក់ដាំប៉េងប៉ោះក្នុងមួយថ្ងៃបាន 364ដើម។ តើក្នុង 7ថ្ងៃគាត់ដាំប៉េងប៉ោះសរុបបានប៉ុន្មានដើម?

364 x 7 = ☐



| | |
|---|---|
| 4 2 | |
| 364 | 7 x 4 = 28 សរសេរលេខ 8 ត្រាទុក 2។ |
| x 7 | 7 x 6 = 42 រួចបូកនឹង 2 ស្មើនឹង 44 សរសេរលេខ 4 ត្រាទុក 4។ |
| 2 548 | 7 x 3 = 21 រួចបូកនឹង 4 ស្មើនឹង 25 សរសេរលេខ 25។ |

មើលវីដេអូ

ដូចនេះកសិករដាំប៉េងប៉ោះសរុបបានចំនួន 2 548ដើម។

2. ចូរបំពេញផលគុណក្នុងប្រអប់

ក) 327 x 3 = ☐ ខ) 473 x 4 = ☐ គ) 168 x 2 = ☐

ឃ) 506 x 5 = ☐ ង) 419 x 3 = ☐ ច) 218 x 4 = ☐

3. ចូរបំពេញផលគុណក្នុងប្រអប់

ក) 705 x 2 = ☐ ខ) 273 x 5 = ☐ គ) 586 x 3 = ☐

ឃ) 190 x 5 = ☐ ង) 638 x 3 = ☐ ច) 917 x 2 = ☐

4. ចូរបំពេញផលគុណក្នុងប្រអប់

ក) 167 x 6 = ☐ ខ) 290 x 8 = ☐ គ) 631 x 7 = ☐

ឃ) 549 x 9 = ☐ ង) 706 x 6 = ☐ ច) 427 x 8 = ☐

5. ចូរបំពេញផលគុណក្នុងប្រអប់

ក) 372 x 7 = ☐ ខ) 631 x 9 = ☐ គ) 529 x 6 = ☐

ឃ) 278 x 7 = ☐ ង) 845 x 8 = ☐ ច) 900 x 9 = ☐

6. ចូរបំពេញផលគុណក្នុងប្រអប់

ក) 509 x 4 = ☐ ខ) 485 x 6 = ☐ គ) 362 x 9 = ☐ ឃ) 816 x 7 = ☐ ង) 245 x 3 = ☐ ច) 371 x 8 = ☐

# ហ្វឹកហាត់ការគុណចំនួនមានលេខ 3ខ្ទង់នឹង 1ខ្ទង់គ្មាន និងមានត្រាទុក

1. **ល្បែងស្វែងរករូបភាពអាថ៌កំបាំង**

**របៀបលេង៖**

១) គណនាផលគុណពី ក) ដល់ ញ)។

២) ផ្ទៀងផ្ទាត់ផលគុណជាមួយចំនួននៅក្នុងតារាង និងផាត់ពណ៌ក្រឡានោះ។

ក) 615 x 6 = ☐  ខ) 207 x 9 = ☐  គ) 394 x 2 = ☐  ឃ) 781 x 5 = ☐  ង) 495 x 7 = ☐

ច) 329 x 3 = ☐  ឆ) 742 x 8 = ☐  ជ) 474 x 4 = ☐  ឈ) 620 x 5 = ☐  ញ) 863 x 7 = ☐




មើលវីដេអូ

៣) នៅពេលផាត់ពណ៌គ្រប់ចំនួន រូបភាពដែលអ្នករកឃើញគឺ៖_______________។

2. ចូរបំពេញប្រអប់ខាងក្រោមដោយបង្វិលថាសបង្កើតជាចំនួនមានលេខ 3ខ្ទង់ រួចដោះស្រាយចំណោទ

មើលវីដេអូ

ក) មាន់របស់ពូឈានពងក្នុងមួយថ្ងៃបាន ☐☐☐ គ្រាប់។
តើក្នុង 7ថ្ងៃមាន់របស់ពូឈានពងបានប៉ុន្មានគ្រាប់?
មាន់របស់ពូឈានពងបានចំនួន ___________ គ្រាប់។

☐☐☐ x ☐ = ☐

ខ) កសិករម្នាក់ដាំកូនឈើបាន 2☐☐ ដើមក្នុងមួយថ្ងៃ។
តើក្នុង 9ថ្ងៃគាត់ដាំកូនឈើសរុបបានប៉ុន្មានដើម?
កសិករដាំកូនឈើសរុបបានចំនួន _________ ដើម។

☐☐☐ x ☐ = ☐




គ) សិប្បកម្មឡឥដ្ឋមួយផលិតឥដ្ឋបាន ☐☐☐ ដុំក្នុងមួយថ្ងៃ។
តើក្នុង 6ថ្ងៃសិប្បកម្មនោះផលិតឥដ្ឋសរុបបានប៉ុន្មានដុំ?
សិប្បកម្មនោះផលិតឥដ្ឋបានចំនួន ___________ ដុំ។

☐☐☐ x ☐ = ☐

# មេរៀនទី 10 ធរណីមាត្រ

## រំឭកអំពីធរណីមាត្រដែលបានរៀននៅថ្នាក់ទី២

**គួរចងចាំ**



ខ្សែកោង

បន្ទាត់តែងតែត្រង់ជានិច្ច។ បន្ទាត់គ្មានព្រំដែនទេ។

ក ខ

**អង្កត់**គឺជាផ្នែកមួយនៃបន្ទាត់។ អង្កត់មានចំណុចចុងពីរ។

ក ខ

អង្កត់ **កខ**



ខ្សែត្រង់

1. ចូរភ្ជាប់ចំណុចទាំងនេះ រួចសរសេរឈ្មោះអង្កត់នីមួយៗ

**ឧទាហរណ៍**




ឈ្មោះអង្កត់៖ កខ ខគ គឃ

ក)




ឈ្មោះអង្កត់៖ ____

មើលវីដេអូ

ខ)




ឈ្មោះអង្កត់៖ ____ ____ ____ ____

គ)




ឈ្មោះអង្កត់៖ ____ ____ ____ ____

ឃ)




ឈ្មោះអង្កត់៖ ____ ____ ____

2. ចូរសរសេរឈ្មោះរូបធរណីមាត្រមានវិមាត្រពីរ និងវិមាត្របី

ត្រីកោណ ស៊ីឡាំង ការេ ប្រលេពីប៉ែតកែង ស្វ៊ែរ ចតុកោណកែង រង្វង់ កោន គូប

ក)  ____

ខ)  ____

គ)  ____

ឃ)  ____

មើលវីដេអូ

ង)  ____

ច)  ____

ឆ)  ____

ជ)  ____

ឈ)  ____

# ការកំណត់សញ្ញាណនៃការេ និងចតុកោណកែង

**គួរចងចាំ**




**ចតុកោណកែង** គឺជាចតុកោណដែលមានជ្រុងបួន និងមុំកែងបួន។

ជ្រុងវែងរបស់ចតុកោណកែងហៅថា **បណ្តោយ** ( **ជ្រុង កខ = គឃ** )

ជ្រុងខ្លីរបស់ចតុកោណកែងហៅថា **ទទឹង** ( **ជ្រុង ខគ = ឃក** )

បន្ទាត់នៅចន្លោះមុំកែងឈមគ្នាហៅថា **អង្កត់ទ្រូង អង្កត់ កគ = ខឃ**

**មុំកែងទាំងបួនរបស់ចតុកោណកែងនេះគឺ មុំ ក ខ គ ឃ**




**ការេ** គឺជាចតុកោណដែលមាន**ជ្រុងបួនស្មើគ្នា** និងមុំកែងបួន។

**ការេ** មានលក្ខណៈដូចទៅនឹងចតុកោណកែងដែរ ប៉ុន្តែជ្រុងទាំងបួនរបស់ការេមានប្រវែងស្មើៗគ្នា។ **ជ្រុង កខ = ខគ = គឃ = ឃក**

**សម្គាល់៖** យើងអាចនិយាយថា ជ្រុង **កខ** ក៏បាន ឬជ្រុង **ខក** ក៏បាន។

មើលវីដេអូ

1. ចូរបំពេញចន្លោះ និងសរសេរឈ្មោះអង្កត់នៅក្នុងប្រអប់







ក ) ការេមានជ្រុង __ ស្មើគ្នា [ ] [ ] [ ] [ ] និងមានអង្កត់ទ្រូង __ អង្កត់ [ ] [ ] ។

ខ ) ចតុកោណកែងមានជ្រុងវែង __ គឺជ្រុង [ ] [ ] និងជ្រុង ____ __ គឺជ្រុង [ ] [ ] ។

គ ) អង្កត់ទ្រូងនៃចតុកោណកែងគឺអង្កត់ [ ] [ ] ។

ឃ ) ការេ និងចតុកោណកែងមានមុំកែង____ ។

2. **សកម្មភាព៖ ស្វែងរករូបការេ**

ចូរមើលតារាងដើម្បីស្វែងរក**ការេ** រួចសរសេរអក្សរនៃឈ្មោះការេនោះនៅក្នុងប្រអប់។ តើអ្នកអាចរកឃើញការេចំនួនប៉ុន្មាន? [ ]

| | | |
|---|---|---|
| ក | ខ | គ |
| ឃ | ង | ច |
| ឆ | ជ | ឈ |

ក [ ] [ ] [ ] [ ] [ ] [ ] [ ] [ ]

កខឃង [ ] [ ] [ ]

[ ]

3. **សកម្មភាព៖ ស្វែងរករូបចតុកោណកែង។** តើអ្នកអាចរកឃើញចតុកោណកែងចំនួនប៉ុន្មាន?

កខ [ ] [ ] [ ] [ ] [ ] [ ] [ ] [ ] [ ] [ ] [ ]

កខគ [ ] [ ] [ ] [ ] [ ]

កខគឃងច [ ] [ ] [ ]

**តើមានចតុកោណកែងទាំងអស់** ចំនួនប៉ុន្មាន? [ ]

# ការកំណត់សញ្ញាណ និងលក្ខណៈនៃបន្ទាត់កែង

**គួរចងចាំ**



**បន្ទាត់កែង**









**បន្ទាត់ពីរជួបគ្នាបង្កើតបានមុំកែងមួយ ហៅថា បន្ទាត់កែង។**



**មុំទាំងអស់របស់ការេ និង ចតុកោណកែងគឺជាមុំកែង**

មើលវីដេអូ

1. ចូរគូស ⌝ រួចគូសរង្វង់ជុំវិញបន្ទាត់កែង
ផ្ទៀងផ្ទាត់ចម្លើយរបស់អ្នកជាមួយក្រឡាការេ ឬកែងនៃសន្លឹកក្រដាស

ឧទាហរណ៍






2. ចូរគូស ⌝ សម្រាប់បន្ទាត់កែង រួចសរសេរឈ្មោះគូនៃបន្ទាត់កែងនោះ

ឧទាហរណ៍







ក) ______ ______

ខ) ______ ______

គ) ______ ______

ឃ) ______ ______

3. ចូរប្រើបន្ទាត់ដើម្បី ក) គូសបន្ទាត់កែងនៅលើក្រឡាការេ
ខ) បង្កើតបន្ទាត់កែងដោយខ្លួនឯង





មើលវីដេអូ

# កំណត់ និងគូសបន្ទាត់ស្រប

**គួរចងចាំ**

បន្ទាត់ស្រប






បន្ទាត់ស្របតែងតែ មានចន្លោះស្មើគ្នា



ជ្រុងឈមគ្នារបស់ការេ និង ចតុកោណកែង គឺជាបន្ទាត់ស្រប

មើលវីដេអូ

1. ចូរប្រាប់ឈ្មោះគូនៃបន្ទាត់ស្របខាងក្រោម

ឧទាហរណ៍




ឃគ និង ឆជ




ក) ______ ខ) ______ គ) ______

2. ចូរមើលរូបភាព និងឆ្លើយសំណួរខាងក្រោម



មើលវីដេអូ

ក) ចូររកមើលបន្ទាត់កែង និងគូសសញ្ញា ∟ នៅលើរូបភាពដើម្បីបង្ហាញថាបន្ទាត់ពីរនោះកែងគ្នា។

ខ) ចូរគូសសញ្ញា /\ នៅលើរូបភាពដើម្បីបង្ហាញថាបន្ទាត់ពីរស្របគ្នា។ តើមានបន្ទាត់ស្របចំនួនប៉ុន្មាន? ______

គ) តើអ្នករកឃើញមុំកែងចំនួនប៉ុន្មាន? ______

# ការសង់កម្ពស់ត្រីកោណ

**គួរចងចាំ**

ត្រីកោណតែងតែមាន
ជ្រុងបី
កំពូលបី
និងកម្ពស់




ដើម្បីសង់កម្ពស់ត្រីកោណ យើងត្រូវ៖

១) កំណត់យកជ្រុងណាមួយជាបាតរបស់ត្រីកោណ (ឧ. ជ្រុង **កខ**)។

២) រកកំពូលដែលឈមនឹងបាត (ឧ. កំពូល **គ**)។

៣) ប្រើកែងដើម្បីគូសបន្ទាត់ចេញពីកំពូល **គ** ទៅកែងបាត **កខ** ឬ បន្លាយនៃបាត **កខ**។

៤) កម្ពស់របស់ត្រីកោណគឺអង្កត់ **គឃ**។

**ឧទាហរណ៍ទី1**




**ឧទាហរណ៍ទី2**




**សកម្មភាព៖ សង់កម្ពស់នៃត្រីកោណ**

មើលវីដេអូ

១) ចូរភ្ជាប់ចំណុចទាំងនេះដើម្បីបង្កើតជាត្រីកោណ។

២) ប្រើកែង ឬបន្ទាត់ដើម្បីគូសបន្ទាត់ចេញពីកំពូលទៅកែងនឹងបាត (ឧទាហរណ៍ទី1) ឬទៅកែងនឹងបន្លាយនៃបាត (ឧទាហរណ៍ទី2)។

៣) គូសសញ្ញា ⌞ ត្រង់ចំណុចកែង និងសរសេរអក្សរសម្គាល់ (**ឃ**)។

**សូមចាំថា** ត្រីកោណខ្លះមានជ្រុងពីរកែងគ្នារួចហើយ។



# ការសង់ត្រីកោណដោយស្គាល់ប្រវែងជ្រុងមួយ

**គួរចងចាំ**



យើងប្រើដែកឈានដើម្បីគូស**រង្វង់** និង**ធ្នូ**។



ធ្នូគឺជាផ្នែកមួយនៃរង្វង់



ចំណុចដែលធ្នូ 2 កាត់គ្នា ហៅថា **ចំណុចប្រសព្វ**។

**ការសង់ត្រីកោណដោយស្គាល់ជ្រុងមួយ**




គូសធ្នូមួយដោយដាក់ចុងស្រួចរបស់ដែកឈានត្រង់ចំណុច **ក**




គូសធ្នូមួយទៀតឱ្យកាត់ធ្នូទី១ដោយដាក់ចុងស្រួចរបស់ដែកឈាននៅចំណុច **ខ**




ដៅអក្សរសម្គាល់ ឌ. **គ** រួចគូសបន្ទាត់ភ្ជាប់ចំណុចទាំងបី

មើលវីដេអូ

**សកម្មភាព៖ សង់ត្រីកោណដោយស្គាល់ជ្រុងមួយ**

ចូរសង់ត្រីកោណខាងក្រោមដោយធ្វើតាមការណែនាំខាងលើ

ក ―――――――― ខ

ក ―――――――――― ខ

ក ――――― ខ

ក ―――――――― ខ

ក ―――――――― ខ

# ការសង់ត្រីកោណដោយស្គាល់ប្រវែងជ្រុងបី

**គួរចងចាំ**

ជ្រុង **កខ** ប្រវែង 6សម

ជ្រុង **កគ** ប្រវែង 5សម

ជ្រុង **ខគ** ប្រវែង 5សម




១) គូសជ្រុង **កខ** ប្រវែង 6សម។



២) វាស់ប្រវែង 5សម។




៣) គូសធ្នូប្រវែង 5សមពីចំណុច **ក**។




៤) គូសធ្នូប្រវែង 5សម ពីចំណុច **ខ**។




៥) សរសេរអក្សរសម្គាល់ចំណុច ខ្ញុ. **គ**។

៦) គូសបន្ទាត់ភ្ជាប់ចំណុចទាំងបី **កគខ**។

1. ចូរសង់ត្រីកោណ និងកម្ពស់របស់វាតាមប្រវែងដែលឱ្យខាងក្រោម

មើលវីដេអូ

**ឧទាហរណ៍**




**ក** ______________________ **ខ**

១) ជ្រុង **កខ** = 5សម

ជ្រុង **កគ** = 5សម

ជ្រុង **គខ** = 5សម

**ក** ______________________ **ខ**

៣) ជ្រុង ក**ខ** = 6សម

ជ្រុង **កគ** = 8សម

ជ្រុង **គខ** = 10សម

**ក** ______________________ **ខ**

២) ជ្រុង **កខ** = 5សម

ជ្រុង **កក** = 4សម

ជ្រុង **គខ** = 8សម



facebook.com/moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ការណែនាំអំពីបរិមាត្រ

**គួរចងចាំ**




បរិមាត្រ = 3 + 2 + 3 + 2

បរិមាត្រ = 10សម




បរិមាត្រ = 3 + 1 + 2 + 1 + 3 +1 +1 +1 + 7 + 2

បរិមាត្រ = 22សម

មើលវីដេអូ

1. ចូរគណនាបរិមាត្រនៃរូបដែលបានផាត់ពណ៌ខាងក្រោម ដោយដឹងថាប្រវែងជ្រុងនៃការេនីមួយៗគឺ **1សម**




| | | | |
|---|---|---|---|
| ក) | ខ) | គ) | ឃ) |

2. ក) ចូរគូស និងផាត់ពណ៌រូបធរណីមាត្ររបស់អ្នក។
   ខ) ចូរគណនា និងសរសេរបរិមាត្រនៃរូបធរណីមាត្រនីមួយៗ។






មើលវីដេអូ

# ការគណនាបរិមាត្រត្រីកោណ ការេ និងចតុកោណកែង

**គួរចងចាំ**




**កខ + ខគ + គក**

3 + 3 + 3 = **9សម**




**កខ + ខគ + គឃ + ឃក**

3 + 3 + 3 + 3 = **12សម**




**កខ + ខគ + គឃ + ឃក**

4 + 2 + 4 + 2 = **12សម**




**កខ + ខគ + គឃ + ឃក**

1 + 3 + 1 + 3 = **8សម**

**បរិមាត្រ គឺជាប្រវែងជុំវិញនៃរូបធរណីមាត្រវិមាត្រពីរ។**

មើលវីដេអូ

1. ចូរគណនាបរិមាត្ររូបធរណីមាត្រខាងក្រោមដោយបូកប្រវែងជ្រុងនីមួយៗបញ្ចូលគ្នា




ក)




ខ)




គ)




ឃ)

2. ចូរវាស់ប្រវែងជ្រុងរូបធរណីមាត្រខាងក្រោម និងរកបរិមាត្រដោយគិតជាសង់ទីម៉ែត្រ




ក)




ខ)



គ)

មើលវីដេអូ




ឃ)




ង)



ច)

# ការគណនាបរិមាត្រនៃការេ និងចតុកោណកែងដោយប្រើវិធីបូក និងវិធីគុណ

**គួរចងចាំ**




បូកប្រវែងនៃជ្រុងនីមួយៗ

**កខ + ខគ + គឃ + ឃក**

3 + 3+ 3 + 3 = **12សម**

**ឬ**

ប្រវែងជ្រុង **x 4**

3 x 4 = **12សម**

មើលវីដេអូ

**បរិមាត្រការេ = ជ្រុង x 4**




បូកប្រវែងនៃជ្រុងនីមួយៗ

**កខ + ខគ + គឃ + ឃក**

2 + 5 + 2 + 5 = **14សម**

**ឬ**

(បណ្ដោយ + ទទឹង ) x 2

5 + 2 = **7**

**7** x 2 = **14សម**

**បរិមាត្រចតុកោណកែង = (បណ្ដោយ + ទទឹង ) x 2**

1. ចូរគណនាបរិមាត្រដោយប្រើវិធីគុណ រួចបំពេញនៅក្នុងប្រអប់

ក)




☐ x ☐ = ☐

បរិមាត្រការេ គឺ ☐

ខ)




☐ + ☐ = ☐

☐ x ☐ = ☐

បរិមាត្រចតុកោណកែង គឺ ☐

2. ចូរវាស់ប្រវែងជ្រុងរូបធរណីមាត្រខាងក្រោម រួចបំពេញប្រអប់ និងគណនារកបរិមាត្រ

ក)




**កខ** = ☐ សម

**បរិមាត្រ** គឺ ☐ x ☐

**បរិមាត្រ** = ☐ សម

មើលវីដេអូ

ខ)




**កខ** = ☐ សម **កឃ** = ☐ សម

☐ + ☐ = ☐

☐ x ☐ = ☐

**បរិមាត្រ** = ☐ សម

គ)




**កខ** = ☐ សម **កឃ** = ☐ សម

☐ + ☐ = ☐

☐ x ☐ = ☐

**បរិមាត្រ** = ☐ សម

# ការគណនាផ្ទៃក្រឡារូបធរណីមាត្រដោយរាប់ចំនួនការេ

**គួរចងចាំ**

ខ្នាតផ្ទៃក្រឡារបស់យើងពេលនេះគឺ**សង់ទីម៉ែត្រការេ**

ផ្ទៃក្រឡាគឺជា**ទំហំផ្ទៃរាប**នៃរូបធរណីមាត្រមួយ

ជ្រុងនីមួយៗរបស់ការេនេះ មានប្រវែង**មួយសង់ទីម៉ែត្រ**។



ផ្ទៃក្រឡារបស់ការេនេះស្មើនឹង **មួយសង់ទីម៉ែត្រការេ**។ យើងសរសេរកាត់ **1cm²**

មើលវីដេអូ





ផ្ទៃក្រឡារបស់ការេនេះគឺ **ប្រាំបួនសង់ទីម៉ែត្រការេ** ឬ **9cm²**

ផ្ទៃក្រឡារបស់ចតុកោណកែងនេះគឺ **ប្រាំបួនសង់ទីម៉ែត្រការេ** ឬ **9cm²**

1. ចូរគណនាផ្ទៃក្រឡានៃរូបភាពខាងក្រោមដោយដឹងថាជ្រុងនីមួយៗនៃ ▢ = 1cm

**ឧទាហរណ៍**



ផ្ទៃក្រឡា = 8cm²

ក)



ផ្ទៃក្រឡា =

ខ)



ផ្ទៃក្រឡា =

គ)



ផ្ទៃក្រឡា =

ឃ)



ផ្ទៃក្រឡា =




| ផ្ទៃក្រឡា = | ផ្ទៃក្រឡា = | ផ្ទៃក្រឡា = | ផ្ទៃក្រឡា = |
|---|---|---|---|


ទំព័រនេះទំនេរ ព្រោះទំព័របន្ទាប់អ្នកត្រូវ
កាត់ដើម្បីបង្កើតគ្រាប់ឡុកឡាក់។

# បង្កើតគ្រាប់ឡុកឡាក់របស់អ្នក




**ការណែនាំ៖**

**សម្ភារ៖** កន្ត្រៃ ការ ឬស្កុតសម្រាប់បិទ

១) កាត់រូបនៅទំព័រនេះ។

២) កាត់ចតុកោណកែងធំចេញ។

៣) កាត់រូបពន្លាតនៃគូបចេញ។

៤) បត់តាមខ្សែបន្ទាត់កន្លែងដែលទុកបិទការ។

៥) ដាក់ការនៅកន្លែងបិទការទី 1។

៦) ដាក់ការនៅកន្លែងបិទការទី 2។

៧) ដាក់ការនៅកន្លែងបិទការទី 3។

មើលវីដេអូ



# ការគណនាផ្ទៃក្រឡាការេ និងចតុកោណកែងដោយយកបណ្ដោយ x ទទឹង

មើលវីដេអូ

**គួរចងចាំ**




**ផ្ទៃក្រឡា = បណ្ដោយ x ទទឹង**

$5cm \times 3cm = 15cm^2$

ផ្ទៃក្រឡា = **$15cm^2$**

1. ចូរបំពេញប្រអប់ និងគណនារកផ្ទៃក្រឡា

ក)




☐ x ☐

ផ្ទៃក្រឡា = ☐

ខ)




☐ x ☐

ផ្ទៃក្រឡា = ☐

គ)




☐ x ☐

ផ្ទៃក្រឡា = ☐

ឃ)




☐ x ☐

ផ្ទៃក្រឡា = ☐

ង)




☐ x ☐

ផ្ទៃក្រឡា = ☐

---

**ល្បែងគណនាផ្ទៃក្រឡា** (លេងជាដៃគូ)

**សម្ភារៈ៖** គ្រាប់ឡុកឡាក់ ក្ដារឆ្នួន ឬក្រដាសសម្រាប់កត់ត្រា

**របៀបលេង៖** សន្មតយកភ្នែកគ្រាប់ឡុកឡាក់តាងឱ្យប្រវែងជ្រុង (ឧទាហរណ៍ ⚄ តាងឱ្យ 5cm)

១) ប្ដូរវេនគ្នាបោះគ្រាប់ឡុកឡាក់ម្នាក់ពីរដង និងគូររូបចតុកោណកែង ឬការេ ទៅតាមប្រវែងដែលបោះបាននោះ។

២) សរសេរប្រវែងជ្រុងនៅតាមជ្រុងនីមួយៗ។

៣) គណនារកផ្ទៃក្រឡានៃរូបធរណីមាត្រនោះ និងសរសេរចម្លើយដាក់នៅលើរូបនីមួយៗ។

៤) ផ្ទៀងផ្ទាត់លទ្ធផលគ្នា។ អ្នកដែលមាន**ផ្ទៃក្រឡាធំជាងគេ**ទទួលបាន 1ពិន្ទុ។

៥) លុបក្ដារឆ្នួនចេញ និងបន្តលេងរហូតមានអ្នកទទួលបាន **3ពិន្ទុ**មុនគេ គឺជាអ្នកឈ្នះ។

មើលវីដេអូ

**ឧទាហរណ៍**



# ការគណនាផ្ទៃក្រឡារូបធរណីមាត្រគិតជា $m^2$

**គួរចងចាំ**

**ម៉ែត្រការេ**គឺជាឯកតារង្វាស់ផ្ទៃក្រឡា។ យើងសរសេរកាត់ **$m^2$** ។

100cm ឬ **1m**

100cm ឬ **1m**




យើង**រាប់**ចំនួនការេដើម្បីរកផ្ទៃក្រឡា

 តាងឱ្យ **$1m^2$**



ផ្ទៃក្រឡា = **$12m^2$**

របៀបគណនាផ្ទៃក្រឡា

**8m**

**6m**



**ផ្ទៃក្រឡា = បណ្តោយ x ទទឹង**

**8 x 6 = 48**

**ដូចនេះផ្ទៃក្រឡា = $48m^2$**

1. ចូររកផ្ទៃក្រឡា ដោយដឹងថា  = $1m^2$

ក)



ផ្ទៃក្រឡា = ______ $m^2$

ខ)



ផ្ទៃក្រឡា = ______ $m^2$

គ)



ផ្ទៃក្រឡា = ______ $m^2$

2. ចូរគណនាផ្ទៃក្រឡារូបភាពខាងក្រោម

មើលវីដេអូ

ក)

13m

3m



☐ x ☐

ផ្ទៃក្រឡា = ______ $m^2$

ខ)

4m

12m



☐ x ☐

ផ្ទៃក្រឡា = ______ $m^2$

គ)

21m

9m



☐ x ☐

ផ្ទៃក្រឡា = ______ $m^2$

# ការគណនាផ្ទៃក្រឡាត្រីកោណដោយការរាប់ចំនួនការេ

**គួរចងចាំ**

**ផ្ទៃក្រឡា**ត្រីកោណស្មើនឹង**ពាក់កណ្ដាលនៃផ្ទៃក្រឡាចតុកោណកែង** ដែលមាន**បាតនិងកម្ពស់ដូចគ្នា**។



ផ្ទៃក្រឡានៃចតុ**កោណកែង** = $12cm^2$

ផ្ទៃក្រឡានៃ**ត្រីកោណ** = $6cm^2$



**សកម្មភាព៖ ការបង្ហាញថាផ្ទៃក្រឡាត្រីកោណគឺស្មើនឹងពាក់កណ្ដាលនៃផ្ទៃក្រឡាចតុកោណកែង**

មើលវីដេអូ

១) ប្រើកន្ត្រៃកាត់រូបទាំងពីរចេញពីផ្នែកខាងក្រោម ដោយកាត់តាមបន្ទាត់ដាច់ៗ។

២) កាត់រូបចតុ**កោណកែងទី១**។

៣) កាត់តាម**បន្ទាត់ដាច់ៗ**នៃអង្កត់ទ្រូង ឥឡូវអ្នកមានត្រីកោណចំនួនពីរ។

៤) ដាក់ត្រីកោណដែលមានពណ៌នៅលើត្រីកោណមួយទៀតដើម្បីបង្កើតឱ្យមានរាងដូចគ្នា (ត្រួតស៊ីគ្នា)។

**អ្នកបានបង្ហាញថាត្រីកោណទី១ គឺស្មើនឹងពាក់កណ្ដាលនៃចតុកោណកែង។**

៥) កាត់តាមបន្ទាត់ជិតនៃត្រីកោណដែលមានពណ៌។

៦) ដាក់រូបដែលមានផាត់ពណ៌របស់ត្រីកោណដែលទើបតែកាត់បានពីរនៅពីលើផ្នែកពណ៌សនៃចតុកោណកែង ដើម្បីបង្កើតបានជាចតុកោណកែងមួយទៀត។

ផ្ទៃក្រឡានៃចតុកោណកែងដែលមានពណ៌នេះគឺ ☐

ផ្ទៃក្រឡានៃត្រីកោណដែលកាត់រួចគឺ ☐



៧) បន្តជាមួយនឹងចតុកោណកែងទី២។

ផ្ទៃក្រឡានៃចតុកោណកែងដែលមានពណ៌គឺ ☐

ផ្ទៃក្រឡានៃត្រីកោណដែលកាត់រួចគឺ ☐



**ចតុកោណកែងទី១**



**ចតុកោណកែងទី២**

# ការគណនាផ្ទៃក្រឡាត្រីកោណដោយការរាប់ចំនួនការេ (ត)

**គួរចងចាំ**





តាងឱ្យ $1cm^2$




មើលវីដេអូ

ផ្ទៃក្រឡាការេ = $16cm^2$

ផ្ទៃក្រឡាការេ = $16cm^2$

ផ្ទៃក្រឡាត្រីកោណ = $16cm^2 \div 2$

ផ្ទៃក្រឡាត្រីកោណ ក = $8cm^2$ ផ្ទៃក្រឡាត្រីកោណ ខ = $8cm^2$

1. ចូររកផ្ទៃក្រឡារូបធរណីមាត្រខាងក្រោមដោយរាប់ចំនួនការេ និងបំពេញចំនួនក្នុងប្រអប់

១)




ផ្ទៃក្រឡាចតុកោណកែង = ☐

ផ្ទៃក្រឡាត្រីកោណ ក = ☐

ផ្ទៃក្រឡាត្រីកោណ ខ = ☐

២)




ផ្ទៃក្រឡាការេ = ☐

ផ្ទៃក្រឡាត្រីកោណ គ = ☐

ផ្ទៃក្រឡាត្រីកោណ ឃ = ☐

# ការគណនាផ្ទៃក្រឡាត្រីកោណដោយគេប្រាប់ផ្ទៃក្រឡាចតុកោណកែង

**គួរចងចាំ**




ផ្ទៃក្រឡាចតុកោណកែង = **បណ្តោយ x ទទឹង**

**6 x 3 = 18**

ដូចនេះ **ផ្ទៃក្រឡាចតុកោណកែង = 18cm²**

ផ្ទៃក្រឡាត្រីកោណ = **ផ្ទៃក្រឡាចតុកោណកែង ÷ 2**

**18 ÷ 2 = 9**

ដូច្នេះ **ផ្ទៃក្រឡាត្រីកោណ = 9cm²**

**ផ្ទៃក្រឡាត្រីកោណ ក = 9cm²**
**ផ្ទៃក្រឡាត្រីកោណ ខ = 9cm²**




ផ្ទៃក្រឡាចតុកោណកែង = **បណ្តោយ x ទទឹង**

**5 x 2 = 10**

ដូចនេះ **ផ្ទៃក្រឡាចតុកោណកែង = 10cm²**

ផ្ទៃក្រឡាត្រីកោណ = **ផ្ទៃក្រឡាចតុកោណកែង ÷ 2**

**10 ÷ 2 = 5**

ដូច្នេះ **ផ្ទៃក្រឡាត្រីកោណ = 5cm²**

**ផ្ទៃក្រឡាត្រីកោណ ក = 5cm²**
**ផ្ទៃក្រឡាត្រីកោណ ខ = 5cm²**

មើលវីដេអូ

1. ចូរគណនាផ្ទៃក្រឡារូបធរណីមាត្រខាងក្រោមដោយបំពេញចំនួនក្នុងប្រអប់

ក)




ផ្ទៃក្រឡាចតុកោណកែង = 7 x ☐ = ☐

= ☐ cm²

ផ្ទៃក្រឡាត្រីកោណ = ផ្ទៃក្រឡាចតុកោណកែង ÷ 2

☐ ÷ 2 = ☐

ផ្ទៃក្រឡាត្រីកោណ = ☐ cm²

ផ្ទៃក្រឡាត្រីកោណ ក = ☐ cm²

ផ្ទៃក្រឡាត្រីកោណ ខ = ☐ cm²

ខ)




ផ្ទៃក្រឡាចតុកោណកែង = 8 x ☐ = ☐

= ☐ cm²

ផ្ទៃក្រឡាត្រីកោណ = ផ្ទៃក្រឡាចតុកោណកែង ÷ 2

☐ ÷ 2 = ☐

ផ្ទៃក្រឡាត្រីកោណ = ☐ cm²

ផ្ទៃក្រឡាត្រីកោណ ក = ☐ cm²

# ការប្តូរខ្នាតផ្ទៃក្រឡាពី m² ទៅ cm² និងច្រាសមកវិញ

**គួរចងចាំ**




មើលវីដេអូ




| m² | cm² |
|---|---|
| 1 | 10 000 |
| 2 | 20 000 |
| 3 | 30 000 |
| 4 | 40 000 |
| 5 | 50 000 |
| 6 | 60 000 |
| 7 | 70 000 |
| 8 | 80 000 |
| 9 | 90 000 |

1. ចូរបំពេញប្រអប់ដោយប្រើតារាងប្តូរខ្នាតពី m² ទៅ cm² នៅក្នុងចំណុចគួរចងចាំ

**ឧទាហរណ៍**




ផ្ទៃក្រឡា = 4m²

4m² = 40 000cm²

ក)




ផ្ទៃក្រឡា = 6m²

6m² = ______

ខ)




ផ្ទៃក្រឡា = 9m²

9m² = ______

គ) 2m² = ______

ឃ) 7m² = ______

ង) 1m² = ______

ច) 4m² = ______

2. ចូរប្តូរខ្នាតពី cm² ទៅ m² និងបំពេញប្រអប់

**ឧទាហរណ៍**

30 000cm² = 3m²

ក) 50 000cm² = ______

ខ) 10 000cm² = ______

គ) 80 000cm² = ______

ឃ) 60 000cm² = ______

**ល្បែងប្តូរខ្នាតផ្ទៃក្រឡា** (លេងជាដៃគូ)

**របៀបលេង៖** ១) សិស្ស ក បង្វិលថាស។

២) សិស្ស ខ អានចំនួនដែលបង្វិលបាន។

៣) សិស្ស ក ប្តូរខ្នាតពី cm² ទៅ m² ឬពី m² ទៅ cm² តាមជាក់ស្តែង។

៤) សិស្ស ខ ផ្ទៀងផ្ទាត់។

មើលវីដេអូ




**ឧទាហរណ៍**



# ការប្តូរខ្នាតផ្ទៃក្រឡាពីសង់ទីអា ទៅអា និងពី អា ទៅហិកតា

**គួរចងចាំ**

មើលវីដេអូ

**សង់ទីអា អា** និង **ហិកតា** គឺជាឯកតារង្វាស់ផ្ទៃក្រឡា។
យើងសរសេរកាត់ **សង់ទីអា** ដោយ (**ca**) **អា** ដោយ (**a**) និង**ហិកតា** ដោយ (**ha**)
**1អា =100m² និង 1ហិកតា = 10 000m²**




| ប្តូរពីសង់ទីអា ទៅអា | |
|---|---|
| សង់ទីអា | អា |
| 100 | 1 |
| 200 | 2 |
| 300 | 3 |
| 400 | 4 |

| ប្តូរពីអា ទៅហិកតា | |
|---|---|
| អា | ហិកតា |
| 100 | 1 |
| 200 | 2 |
| 300 | 3 |
| 400 | 4 |

| ប្តូរពីហិកតា ទៅអា ទៅសង់ទីអា | | |
|---|---|---|
| ហិកតា | អា | សង់ទីអា |
| 1 | 100 | 10 000 |
| 2 | 200 | 20 000 |
| 3 | 300 | 30 000 |
| 4 | 400 | 40 000 |

1. ចូរបំពេញប្រអប់ដោយប្តូរខ្នាតពី**សង់ទីអា** ទៅ**អា**

ក) 100សង់ទីអា = ☐ អា ខ) 300សង់ទីអា = ☐ អា គ) 800សង់ទីអា = ☐ អា

2. ចូរបំពេញប្រអប់ដោយប្តូរខ្នាតពី**អា** ទៅ**សង់ទីអា**

ក) 2អា = ☐ សង់ទីអា ខ) 4អា = ☐ សង់ទីអា គ) 9អា = ☐ សង់ទីអា

3. ចូរបំពេញប្រអប់ដោយប្តូរខ្នាតពី**អា** ទៅ**ហិកតា**

ក) 300អា = ☐ សង់ទីអា ខ) 200អា = ☐ សង់ទីអា គ) 500អា = ☐ សង់ទីអា

4. ចូរបំពេញប្រអប់ដោយប្តូរខ្នាតពី**ហិកតា** ទៅ**អា**

ក) 1ហិកតា = ☐ អា ខ) 3ហិកតា = ☐ អា គ) 6ហិកតា = ☐ អា

5. ចូរបំពេញប្រអប់ដោយប្តូរខ្នាតពី**ហិកតា** ទៅ**អា**

ក) 1ហិកតា = ☐ សង់ទីអា ខ) 4ហិកតា = ☐ សង់ទីអា គ) 7ហិកតា = ☐ សង់ទីអា

6. ចូរប្តូរខ្នាតផ្ទៃក្រឡា និងបំពេញប្រអប់

ក) ចម្ការមួយមានផ្ទៃក្រឡា **4ហិកតា**។ តើចម្ការនោះមានផ្ទៃក្រឡាប៉ុន្មាន**អា**? ☐





ខ) កសិករម្នាក់ដាំពោតលើផ្ទៃដី **200អា** ។ តើផ្ទៃក្រឡាដីនោះមានទំហំប៉ុន្មាន**ហិកតា**? ☐



គ) កសិករម្នាក់ដាំប៉េងប៉ោះលើផ្ទៃដី **30 000សង់ទីអា**។ តើគាត់ដើមប៉េងប៉ោះលើផ្ទៃដីប៉ុន្មាន**អា**? ☐

# ចម្លើយសម្រាប់សៀវភៅលំហាត់ បឋ

## មេរៀនទី ៨ ពេលវេលា

**ទំព័រ២**

ក) 4:45 ម៉ោង 4និង45នាទី
ខ) 2:20 ម៉ោង 2និង20នាទី
គ) 7:35 ម៉ោង 7និង35នាទី
ឃ) 12:05 ម៉ោង 12និង45នាទី
ង) 10:40 ម៉ោង 10និង40នាទី
ច) 1:30 ម៉ោង 1និង30នាទី
ឆ) 4:55 ម៉ោង 4និង55នាទី
ជ) 6:15 ម៉ោង 6និង15នាទី
ឈ) 3:00 ម៉ោង 3
ញ) 8:50 ម៉ោង 8និង50នាទី
ដ) 8:25 ម៉ោង 8និង25នាទី




**ទំព័រ៤**

1. ក) ម៉ោង 6និង16នាទី 6:16
   ខ) ម៉ោង 2និង54នាទី 2:54
   គ) ម៉ោង 12និង36នាទី 12:36
   ឃ) ម៉ោង 5និង9នាទី 5:09
   ង) ម៉ោង 8និង48នាទី 8:48

2.




   ខ) ម៉ោង 3និង43នាទី 3:43
   គ) ម៉ោង 7និង27នាទី 7:27
   ឃ) ម៉ោង 4និង33នាទី 4:33
   ង) ម៉ោង 8និង51នាទី 8:51

**ទំព័រ៥**

1. ក) ម៉ោង 11
   ខ) ម៉ោង 2និង16នាទី
   គ) ម៉ោង 9
   ឃ) ម៉ោង 8និង40នាទី
   ង) ម៉ោង 1និង32នាទី

**ទំព័រ៦**

1. ក) បានលុង
   ខ) 07:30
   គ) 19:10
   ឃ) សែនមនោរម្យ
   ង) 2



2. ក) 9ម៉ោង 15នាទី
   ខ) 7ម៉ោង 30នាទី
   គ) 7ម៉ោង 20នាទី
   ឃ) 3ម៉ោង 15នាទី
   ង) 2ម៉ោង 30នាទី
   ច) 4ម៉ោង 10នាទី
   ឆ) បានលុង
   ជ) កំពង់ចាម

## មេរៀនទី ៩ វិធីគុណ

**ទំព័រ៧**

| | | |
|---|---|---|
| 2x4=8 | 9x3=27 | 2x5=10 |
| 2x4=16 | 3x3=9 | 7x5=35 |
| 8x4=32 | 7x3=21 | 10x5=50 |
| 7x4=28 | 6x3=18 | 5x5=25 |

ចំនួនដែលនៅសល់គឺៈ 26

2. ក) 66 ខ) 62 គ) 48 ឃ) 90 ង) 55 ច) 86

3.



**ទំព័រ៨**

1. ក) 6 + 6 + 6 + 6 = 24
   ខ) 6 + 6 + 6 + 6 + 6 + 6 + 6 = 42

2.



**ទំព័រ៩**

1.



6,2,8,4,0,6,2,8,4,0



2. ចំនួនអាច់កំបាំងគឺៈ 42 7 x 6 = 42

**ទំព័រ១០**

1. ក) 7 + 7 + 7 + 7 + 7 = 35
   ខ) 7 + 7 + 7 + 7 = 28

2.



3. ក) 6 ខ) 56 គ) 3 ឃ) 63

**ទំព័រ១១**

1.



7,4,1,8,5,2,9,6,3,0

**ទំព័រ១១**

2. ក) 4 ខ) 6 គ) 54 ឃ) 48 ង) 9
   ច) 3 ឆ) 42 ជ) 7 ឈ) 56 ញ) 3

3. ចំនួនអាច់កំបាំងគឺៈ 56 7 x 8=56

**ទំព័រ១២**

1. ក) 8 + 8 + 8 + 8 = 32
   ខ) 8 + 8 + 8 + 8 + 8 + 8 + 8 = 56

2.



**ទំព័រ១៣**

1.



8,6,4,2,0,8,6,4,2,0

2. ក) 5 ខ) 8 គ) 36 ឃ) 42 ង) 4
   ច) 9 ឆ) 24 ជ) 9 ឈ) 48 ញ) 7

3. ចំនួនអាច់កំបាំងគឺៈ 48 8 x 6 = 48

**ទំព័រ១៤**

1. ក) 9 + 9 + 9 + 9 + 9 = 45
   ខ) 9 + 9 + 9 + 9 + 9 + 9 + 9 = 63

2.



**ទំព័រ១៥**

1.



9,8,7,6,5,4,3,2,1,0

2. ក) 5 ខ) 8 គ) 36 ឃ) 42 ង) 4
   ច) 9 ឆ) 24 ជ) 9 ឈ) 48 ញ) 7

3. ចំនួនអាច់កំបាំងគឺៈ 36 9 x 4 = 36

**ទំព័រ១៧**

1. ក) 30 ខ) 270 គ) 81
   ឃ) 136 ង) 255 ច) 136

2. ក) 328 ខ) 140 គ) 188
   ឃ) 185 ង) 138 ច) 343

3. ក) 192 ខ) 318 គ) 420
   ឃ) 276 ង) 108 ច) 294

4. ក) 371 ខ) 168 គ) 119
   ឃ) 294 ង) 560 ច) 483


facebook.com/moeys.gov.kh www.moeys.gov.kh youtube.com/moeyscambodia

# ចម្លើយសម្រាប់សៀវភៅលំហាត់ បព

**ទំព័រ១៧**

5. ក) 432 ខ) 496 គ) 304
 ឃ) 320 ង) 152 ច) 600

6. ក) 225 ខ) 270 គ) 153
 ឃ) 414 ង) 531 ច) 729

7. ក) 216គ្រាប់ ខ) 232គម

**ទំព័រ១៨**

ក្រឡាដែលផាត់ពណ៌៖ 438, 432, 140, 343, 465, 774, 144, 259, 510, 152, 224 រូបត្រី

**ទំព័រ១៩**

1. ក) 864 ខ) 488 គ) 639
 ឃ) 505 ង) 990 ច) 302
 ឆ) 804 ជ) 936 ឈ) 550

2. ក) 981 ខ) 1892 គ) 336
 ឃ) 2580 ង) 1257 ច)) 872

3. ក) 1410 ខ) 1365 គ) 1758
 ឃ) 960 ង) 1914 ច) 1834

4. ក) 1002 ខ) 2320 គ) 4417
 ឃ) 4941 ង) 4236 ច) 3416

5. ក) 2604 ខ) 5679 គ) 3174
 ឃ) 1946 ង) 6760 ច) 8100

6. ក) 2036 ខ) 2910 គ) 2858
 ឃ) 5712 ង) 735 ច) 2968

**ទំព័រ២០**

ក្រឡាដែលផាត់ពណ៌៖ 3690, 1863, 788, 3905, 3465, 987, 5936, 1896, 3100, 6041 រូបទូក

## មេរៀនទី 10 ធរណីមាត្រ

**ចំណាំ៖** យើងហៅអង្កត់ **កខ** ក៏បាន ឬអង្កត់ **ខក** ក៏បាន។

**ទំព័រ២១**

1. ក) កខ ខ) កខ ខគ គឃ ឃង
 គ) កខ ខគ គឃ ឃក ឃ) កខ ខគ គក

2. ក) ការេ ខ) កោន គ) ចតុកោណកែង
 ឃ) ស្វ៊ែរ ង) ស៊ីឡាំង ច) រង្វង់ ឆ) គូប
 ឆ) ត្រីកោណ ឆ) ប្រលេពីប៉ែតកែង

**ទំព័រ២២**

1. ក) ជ្រុង 4 គឺ ចឆ ឆជ ជឈ ជច
 អង្កត់ទ្រូង 2 គឺ ចជ និង ឆឈ
 ខ) ជ្រុងវែង 2 គឺ ខគ ឃង និងជ្រុងខ្លី 2 គឺ ខង គឃ
 គ) អង្កត់ទ្រូងចតុកោណកែងគឺ ខឃ និង គង
 ឃ) មានមុំកែង 4

**ទំព័រ២២**

2. ក ខ គ ឃ ង ច ឆ ជ ឈ
 កខឃង ខគងច ឃងជឆ ងចឈជ
 កខគចឈជឆឃកង រកឃើញការេចំនួន 14

3. កខ ខគ ឃង ងច ឆជ ជឈ កឃ ឃឆ ឃង ងជ គច ចឈ
 កខគ ឃងច ឆជឈ កឃឆ ខងជ គចឈ
 កខងជឆឃ ខគចឈជង កខគចងឃ ឃងចឈជឆ
 ចតុកោណកែងទាំងអស់មានចំនួន 22

**ទំព័រ២៣**

1. ក), ខ), ឃ) និង ង) ជាបន្ទាត់កែង

2. ក) កខ កង ខ) ចឆ ឆជ គ) ឈណ ណទ ឃ) នប បផ
 កង ងឃ ឈញ ញដ ណត តថ ពភ ភម

**ទំព័រ២៤**

1. ក) គឃ ងច ខ) ឌណ ដឋ គ) ថទ បផ

2. មុំកែងចំនួន 21



**ទំព័រ២៥**



**ទំព័រ២៧**



**ទំព័រ២៨**

ក) 12សម ខ) 16សម គ) 24សម ឃ) 26សម

**ទំព័រ២៩**

1. ក) 20សម ខ) 24សម គ) 19សម ឃ) 30សម

2. ក) 12សម ខ)13សម គ) 12សម
 ឃ) 24សម ង) 17សម ច) 12សម

**ទំព័រ៣០**

1. ក) 7 x 4 = 28 បរិមាត្រការេ គឺ 28សម
 ខ) 16 + 10 = 26
 26 x 2 = 52 បរិមាត្រចតុកោណកែង គឺ 52សម

2. ក) 4 x 4 = 16 បរិមាត្រ 16សម
 ខ) 5 + 3= 8; 8 x 2 = 16 បរិមាត្រ 16សម
 គ) 6 + 4 = 10; 10 x 2= 20 បរិមាត្រ 20សម

**ទំព័រ៣១**

ក) $12cm^2$ ខ) $5cm^2$ គ) $16cm^2$ ឃ) $15cm^2$
ង) $15cm^2$ ច) $10cm^2$ ឆ) $9cm^2$ ជ) $11cm^2$

**ទំព័រ៣៤**

ក) $40cm^2$ ខ) $16cm^2$ គ) $78cm^2$
គ) $100cm^2$ ឃ) $49cm^2$

**ទំព័រ៣៥**

1. ក) $15m^2$ ខ) $12m^2$ គ) $78m^2$

2. ក) $39m^2$ ខ) $48m^2$ គ) $189m^2$

**ទំព័រ៣៦**

៦) ផ្ទៃក្រឡាចតុកោណកែង = $48cm^2$
 ផ្ទៃក្រឡាត្រីកោណ = $24cm^2$
៧) ផ្ទៃក្រឡាចតុកោណកែង = $48cm^2$
 ផ្ទៃក្រឡាត្រីកោណ = $24cm^2$

**ទំព័រ៣៧**

1. ចតុកោណកែង = $20cm^2$
 ត្រីកោណ ក = $10cm^2$
 ត្រីកោណ ខ = $10cm^2$



2. ការេ = $36cm^2$
 ត្រីកោណ គ = $18cm^2$
 ត្រីកោណ ខ = $18cm^2$



**ទំព័រ៣៨**

1. ក) ផ្ទៃក្រឡាចតុកោណកែង 7 x 4 = 28
 = $28cm^2$
ផ្ទៃក្រឡាត្រីកោណ = ផ្ទៃក្រឡាចតុកោណកែង ÷ 2
 28 ÷ 2 = 14
 ផ្ទៃក្រឡាត្រីកោណ = $14cm^2$
 ផ្ទៃក្រឡាត្រីកោណ ក = $14cm^2$
 ផ្ទៃក្រឡាត្រីកោណ ខ = $14cm^2$

 ខ) ផ្ទៃក្រឡាចតុកោណកែង 8 x = 24
 = $24cm^2$
ផ្ទៃក្រឡាត្រីកោណ = ផ្ទៃក្រឡាចតុកោណកែង ÷ 2
 24 ÷ 2 = 12
 ផ្ទៃក្រឡាត្រីកោណ = $12cm^2$
 ផ្ទៃក្រឡាត្រីកោណ ក = $12cm^2$

**ទំព័រ៣៩**

1. ក) 60 000$cm^2$ ខ) 90 000$cm^2$
 គ) 20 000$cm^2$ ឃ) 70 000$cm^2$
 ង) 10 000$cm^2$ ច) 40 000$cm^2$

2. ក) $5m^2$ ខ) $1m^2$ គ) $8m^2$ ឃ) $6m^2$

**ទំព័រ៤០**

1. ក) 1អា ខ) 3អា គ) 8អា
2. ក) 200សង់ទីអា ខ) 400សង់ទីអា គ) 900សង់ទីអា
3. ក) 3ហិកតា ខ) 2ហិកតា គ) 5ហិកតា
4. ក) 100អា ខ) 300អា គ) 600អា
5. ក) 10 000សង់ទីអា ខ) 40 000សង់ទីអា
 គ) 70 000សង់ទីអា
6. ក) 400អា ខ) 2ហិកតា គ) 300អា

# កូនស្វាឆ្លាតជួយកូនអ្នកឱ្យចេះគិតលេខបានរហ័ស!

កុមាររៀន កុមារចេះ ១ ២ ៣




https://kounsvachhlat.com

## មានវីដេអូសម្រាប់រៀនធ្វើលំហាត់នីមួយៗ

គ្រប់លំហាត់ និងផ្នែកគួរចងចាំនៃមេរៀននីមួយៗនៅក្នុងសៀវភៅលំហាត់ **កូនស្វាឆ្លាត** សុទ្ធតែមានកូដ QR ( ▦ ) ដែលផ្តល់នូវភាពងាយស្រួលក្នុងការចូលមើលវីដេអូ អំពីរបៀបធ្វើលំហាត់ទាំងនោះ ឬដើម្បីរំឭកមេរៀនឡើងវិញ។



អ្នកអាចមើលវីដេអូនៅលើទូរសព្ទ គ្រប់ប្រភេទបានដោយគ្រាន់តែបើកកាមេរ៉ា ឬកម្មវិធីស្កេនកូដ QR ណាមួយ ហើយតម្រង់កាមេរ៉ាទៅរកកូដ QR ( ▦ ) ដែលមានស្រាប់ក្នុងសៀវភៅ។



**ភាសាខ្មែរ**



ថ្នាក់ទី១ ឆមាសទី១


ថ្នាក់ទី១ ឆមាសទី២



មត្តេយ្យ កម្រិតទាប



មត្តេយ្យ កម្រិតខ្ពស់

**គណិតវិទ្យា**



ថ្នាក់ទី១



ថ្នាក់ទី២



ថ្នាក់ទី៣


មត្តេយ្យ

GPE Transforming Education
unesco
វិទ្យាស្ថានបើកទូលាយ Open Institute
បោះពុម្ពឆ្នាំ ២០២៣
9 789924 578376